**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ៦៩៤...

ថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** : ស្តីពីការចាត់បញ្ជូនមន្ត្រីរាជការស៊ីវិលទៅចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល។

**<u>យោង</u>** : លិខិតលេខ ៤៩៦ មស.ស.ករ ចុះថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ឆ្នាំ២០១៨នេះ សាលាភូមិន្ទរដ្ឋបាលនឹងជ្រើសរើសកម្មសិក្សាការីដើម្បីចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាលសរុបចំនួន១៦០នាក់ ព្រមទាំងវគ្គវិក្រឹត្យការមន្ត្រីមធ្យម និងវគ្គវិក្រឹត្យការមន្ត្រីក្រមការសរុបចំនួន១៦០នាក់។ វគ្គបណ្តុះបណ្តាលបន្តនេះ មានរយៈពេល០៩ខែ ដែលក្នុងនោះរួមមានការសិក្សាទ្រឹស្តី ការអនុវត្តជាក់ស្តែង និងការអនុវត្តការងារសកម្មភាពសង្គម។ បេក្ខជនដែលមានបំណងចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាព ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

**I. វគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់**

**ក.វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់**

- មន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ និងនាយករដ្ឋបាលសាលារាជធានី ខេត្ត (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- អតីតភាពការងារយ៉ាងតិច០៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

**ខ.វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល**

- មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌ "ក"
- អតីតភាពការងារយ៉ាងតិច០៣ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

**II. វគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម**

**ក.វគ្គវិក្រឹត្យការមន្ត្រីមធ្យម**

- មន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងជាអភិបាលរងក្រុង ស្រុក ខណ្ឌ នាយករងរដ្ឋបាលសាលារាជធានី ខេត្ត និងនាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ (មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- អតីតភាពការងារយ៉ាងតិច០២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

**ខ.ចន្ទុទិក្រឹត្យការមន្ត្រីក្រមការ**

- មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌ "ខ"
- អតីតភាពការងារយ៉ាងតិច០២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

## III. ការដាក់ពាក្យ

បេក្ខជនជាមន្ត្រីរាជការស៊ីវិលដែលមានបំណងចូលរៀនក្នុងវគ្គបណ្តុះបណ្តាលខាងលើ សូមបញ្ជូនឈ្មោះមកនាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានរដ្ឋបាល តាមរយៈប្រធានអង្គភាពរបស់ខ្លួន ឱ្យបានយ៉ាងយូរត្រឹម<u>ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨</u> និងត្រូវបំពេញបែបបទតាមប្រព័ន្ធ Online តាមរយៈគេហទំព័រសាលាកុមិន្ទរដ្ឋបាល sms.era.gov.kh ចាប់ពី<u>ថ្ងៃទី១២ ខែមីនា ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨</u> ដោយភ្ជាប់ជាមួយនូវសំណុំឯកសារ ដូចខាងក្រោម៖

- ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស បញ្ជាក់ពីការចូលបម្រើការងារក្នុងមុខងារសាធារណៈ
- ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស បញ្ជាក់ពីការតែងតាំងក្នុងមុខតំណែងសម្រាប់វគ្គក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គក្រឹត្យការមន្ត្រីមធ្យម
- ប្រវត្តិរូបសង្ខេបបញ្ជាក់ដោយនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិក ឬអង្គភាពគ្រប់គ្រងមន្ត្រីផ្ទាល់
- លិខិតបង្ហាញហេតុ (Motivation Letter) របស់សាមីខ្លួន
- សញ្ញាបត្រខ្ពស់ជាងគេ (សញ្ញាបត្របណ្ឌិត សញ្ញាបត្រអនុបណ្ឌិត សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្របរិញ្ញាបត្ររង)។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពអានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

**ព្រាក់ សំរឿន**


<u>សូមទំនាក់ទំនង៖</u>

- លោក ងួន គឹមសេង ០១១ ៣២២ ២២៧
- លោក ណាំ ដារ៉ា ០៩៦ ៦ ៧៩៩ ៨៩៩